**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១០៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## បែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៧/០០៧ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ៥១ អនក្រ.បក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងបង្កភាពងាយស្រួលនិងឆាប់រហ័សក្នុងការស្វែងរកទីតាំងផ្លូវនៅលើផែនទីតំបន់ភូមិសាស្ត្រផ្លូវថ្នល់ និងជានារក្សាឱ្យបានច្រើនជាអតិបរមានូវអត្តសញ្ញាណលេខផ្លូវនិងឈ្មោះផ្លូវសំខាន់ៗពីមុនដែលធ្លាប់ប្រើប្រាស់កន្លងមក ព្រមទាំងបង្កភាពងាយស្រួលក្នុងការធ្វើផែនការជួសជុល កែលម្អ និងថែទាំផ្លូវថ្នល់។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- រៀបចំប្រព័ន្ធដាក់លេខផ្លូវថ្មីដើម្បីបំពេញបន្ថែមលើតម្រូវការចាំបាច់ ឆ្លើយតបទៅនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់
- បែងចែកតំបន់ភូមិសាស្ត្រផ្លូវថ្នល់
- កំណត់នីតិវិធីក្នុងការដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងកែប្រែឈ្មោះផ្លូវឬលេខផ្លូវឱ្យមានការឯកភាពគ្នានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែផ្លូវល្បឿនលឿន ដែលត្រូវកំណត់ដោយបទប្បញ្ញត្តិដោយឡែក។

**មាត្រា ៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

**ឈ្មោះផ្លូវ** សំដៅដល់ឈ្មោះផ្ដល់ឱ្យជាផ្លូវការ ដែលប្រើប្រាស់សម្រាប់គោលបំណងសម្គាល់ទីតាំងផ្លូវឬអាសយដ្ឋានផ្លូវក្នុងតំបន់ណាមួយជាក់លាក់។

**លេខផ្លូវ** សំដៅដល់លេខផ្ដល់ឱ្យជាផ្លូវការ ដែលប្រើប្រាស់សម្រាប់គោលបំណងសម្គាល់ទីតាំងផ្លូវឬអាសយដ្ឋានផ្លូវក្នុងតំបន់ណាមួយជាក់លាក់។ លេខផ្លូវត្រូវដាក់តាមលេខរៀងពីតូចទៅធំ មានលក្ខណៈជាលេខសេសឬលេខគូ។

**ផែនទីអាសយដ្ឋានផ្លូវ** សំដៅដល់ផែនទីកំណត់បញ្ជាក់យ៉ាងច្បាស់លាស់អំពីឈ្មោះផ្លូវនិងលេខផ្លូវ ចំណុចចាប់ផ្ដើមនិងចំណុចបញ្ចប់នៃផ្លូវនីមួយៗ ព្រមទាំងបរិក្ខារសំខាន់ៗនៃផ្លូវនីមួយៗផងដែរ។

**អាសយដ្ឋានផ្លូវ** សំដៅដល់ប្រព័ន្ធប្រើប្រាស់សម្រាប់បញ្ជាក់ទីតាំងអគារ ឬ[illegible]ដែល[illegible]នឈ្មោះផ្លូវឬលេខច្រកផ្លូវចូលសំខាន់ៗ។

**ផ្លូវថ្នល់ ហៅថាផ្លូវ** សំដៅដល់ទំហំផ្លូវទាំងមូល រួមមានតួផ្លូវ ទ្រូងផ្លូវ ជាយផ្លូវឬចិញ្ចើមផ្លូវ ស្ពាន ស្ពានអាកាស ស្ពានរំលង ផ្លូវរូង និងកំពង់ចម្លងតភ្ជាប់ផ្លូវថ្នល់។

**ផ្លូវជាតិ** សំដៅដល់ផ្លូវដែលមានចរាចរណ៍ច្រើន៖

ក - ផ្លូវភ្ជាប់ចេញពីរាជធានីភ្នំពេញឆ្ពោះទៅកាន់ក្រុងនៃខេត្តនីមួយៗនៅទូទាំងប្រទេស។

ខ - ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយ ឆ្ពោះទៅកាន់ក្រុងនៃខេត្តមួយទៀត។

គ - ផ្លូវភ្ជាប់ចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ផ្លូវជាតិ។

ឃ- ផ្លូវបែកចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ក្រុងនៃខេត្ត។

ង - ផ្លូវបែកចេញពីផ្លូវជាតិ ឬផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយឆ្ពោះទៅកាន់តំបន់សំខាន់ៗ ដូចជាកំពង់ផែ ស្ថានីយរថភ្លើង អាកាសយានដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស រមណីយដ្ឋានទេសចរណ៍ ច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន តំបន់មានសក្តានុពលសេដ្ឋកិច្ចសំខាន់ៗផ្សេងទៀត។

ច - ផ្លូវសំខាន់ៗរបស់ជាតិ មានចរាចរណ៍ច្រើនដែលកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

**ផ្លូវខេត្ត** សំដៅដល់ផ្លូវដែលមានចរាចរណ៍មធ្យម៖

ក- ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយ ឆ្ពោះទៅកាន់ទីរួមស្រុក ខណ្ឌ។

ខ- ផ្លូវបែកចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ផ្លូវខេត្ត។

គ- ផ្លូវបែកចេញពីផ្លូវខេត្តឬផ្លូវក្រុង ឆ្ពោះទៅកាន់ទីរួមស្រុក ខណ្ឌ។

ឃ- ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយ ឆ្ពោះទៅកាន់ផ្លូវខេត្ត។

ង- ផ្លូវបែកចេញពីផ្លូវខេត្ត ឆ្ពោះទៅកាន់ផ្លូវខេត្ត។

ច- ផ្លូវបែកចេញពីផ្លូវខេត្តឬផ្លូវក្រុង ឬផ្លូវទីរួមស្រុកនៃខេត្ត ឆ្ពោះទៅកាន់តំបន់សំខាន់ៗ ដូចជាកំពង់ផែ ស្ថានីយរថភ្លើង អាកាសយានដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស រមណីយដ្ឋានទេសចរណ៍ ច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន តំបន់មានសក្តានុពលសេដ្ឋកិច្ចមធ្យមផ្សេងទៀត។

**ផ្លូវរាជធានី ផ្លូវក្រុង និងផ្លូវទីរួមស្រុកនៃខេត្ត** សំដៅដល់ផ្លូវថ្នល់ដែលស្ថិតនៅក្នុងបរិវេណភូមិសាស្ត្ររដ្ឋបាលរាជធានី ខេត្ត ដោយរួមមានទ្រូងផ្លូវ ចិញ្ចើមផ្លូវ និងផ្លូវថ្មើរជើង។

**ផ្លូវជនបទ** សំដៅដល់៖

ក - ផ្លូវដែលភ្ជាប់ពីផ្លូវជាតិ ផ្លូវខេត្ត ឆ្ពោះទៅកាន់ក្រុង ទីរួមស្រុក ខណ្ឌ ទីប្រជុំជនឃុំ សង្កាត់ និងទៅភូមិ។

ខ - ផ្លូវដែលភ្ជាប់ពីក្រុង ទីរួមស្រុក ខណ្ឌ ឆ្ពោះទៅកាន់ក្រុង ទីរួមស្រុក ខណ្ឌ។

គ - ផ្លូវដែលភ្ជាប់ពីក្រុង ទីរួមស្រុក ខណ្ឌ ទៅទីប្រជុំជនឃុំ សង្កាត់។

ឃ- ផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំ សង្កាត់ ទៅទីប្រជុំជនឃុំ សង្កាត់។

ង - ផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំ សង្កាត់ ទៅភូមិ។

ច - ផ្លូវដែលភ្ជាប់ពីភូមិទៅភូមិ។

ឆ - ផ្លូវក្នុងភូមិ។

**ផ្លូវល្បឿនលឿន** សំដៅដល់ផ្លូវសម្រាប់យានយន្តធ្វើចរាចរណ៍ មានបរិក្ខារចែកទ្រូងផ្លូវជាពីរចំណែកខុសទិសគ្នាឬចែកជាគន្លងផ្លូវ គ្មានកន្លែងផ្លូវប្រសព្វលើផ្ទៃរាបមួយឬត្រូវមានផ្លូវប្រសព្វតិចបំផុតក្នុងករណីចាំបាច់ និងបំពាក់គ្រប់គ្រាន់នូវបរិក្ខារផ្លូវថ្នល់ ដើម្បីធានាលំហូរចរាចរណ៍អត់ឈប់ សុវត្ថិភាព និងដើម្បីបន្ថយពេលវេលាធ្វើដំណើរ និងមានកន្លែងកំណត់សម្រាប់ឱ្យយានយន្តចេញនិងចូលផ្លូវល្បឿនលឿន។

**សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់** សំដៅដល់ក្រសួងទទួលបន្ទុកវិស័យផ្លូវថ្នល់និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានទទួលប្រតិភូកម្មអំណាចពីក្រសួងទទួលបន្ទុកវិស័យផ្លូវថ្នល់។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

### មាត្រា ៥.-

សមត្ថកិច្ចក្នុងការដាក់ឈ្មោះផ្លូវឬលេខផ្លូវនិងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ ត្រូវបានកំណត់ដូចខាងក្រោម៖

១ - ក្រសួងទទួលបន្ទុកវិស័យផ្លូវថ្នល់

- ក្រសួងសាធារណការនិងដឹកជញ្ជូនមានសមត្ថកិច្ចដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងកែប្រែឈ្មោះផ្លូវឬលេខផ្លូវដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន និងដាក់ឈ្មោះផ្លូវឬលេខផ្លូវផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន
- ក្រសួងអភិវឌ្ឍន៍ជនបទមានសមត្ថកិច្ចដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងកែប្រែឈ្មោះផ្លូវឬលេខផ្លូវដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន និងដាក់ឈ្មោះផ្លូវឬលេខផ្លូវផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

២ - រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានទទួលប្រតិភូកម្មអំណាចពីក្រសួងទទួលបន្ទុកវិស័យផ្លូវថ្នល់ មានសមត្ថកិច្ចដាក់ឈ្មោះផ្លូវឬលេខផ្លូវនិងកែប្រែឈ្មោះផ្លូវឬលេខផ្លូវក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

### មាត្រា ៦.-

សមត្ថកិច្ចក្នុងការដាក់ឈ្មោះផ្លូវឬលេខផ្លូវនិងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ ដូចមានចែងក្នុងមាត្រា៥ខាងលើ ត្រូវបង្កើតគណៈកម្មាធិការសិក្សាស្រាវជ្រាវនិងរៀបចំបញ្ជីផ្លូវដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ដើម្បីដាក់ស្នើសុំគោលការណ៍ឯកភាពពីរាជរដ្ឋាភិបាលក្នុងការដាក់ឈ្មោះផ្លូវឬលេខផ្លូវនិងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ។ ដោយឡែក ចំពោះផ្លូវទើបសាងសង់ថ្មី ត្រូវស្នើសុំដាក់ឈ្មោះផ្លូវឬលេខផ្លូវមុនពេលចាប់ផ្តើមសាងសង់ឬក្រោយពេលសាងសង់រួចរាល់ជាស្ថាពរ។

គណៈកម្មាធិការសិក្សាស្រាវជ្រាវនិងរៀបចំបញ្ជីផ្លូវ ត្រូវបង្កើតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យផ្លូវថ្នល់។

គណៈកម្មាធិការសិក្សាស្រាវជ្រាវនិងរៀបចំបញ្ជីផ្លូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបង្កើតដោយដីការបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

## ជំពូកទី៣
## ការកំណត់តំបន់ភូមិសាស្ត្រផ្លូវថ្នល់

**មាត្រា ៧.-**

តំបន់ភូមិសាស្ត្រផ្លូវថ្នល់ ត្រូវបានកំណត់និងបែងចែកតាមខ្សែបន្ទាត់ទន្លេមេគង្គនិងទន្លេសាប ជា៣(បី)តំបន់ ដូចខាងក្រោម៖

១- តំបន់១ ស្ថិតនៅទិសនិរតី ក្នុងចន្លោះទន្លេមេគង្គក្រោមនិងទន្លេសាប តាងដោយលេខ "១"។

២- តំបន់២ ស្ថិតនៅទិសពាយ័ព្យ ក្នុងចន្លោះទន្លេមេគង្គលើនិងទន្លេសាប តាងដោយលេខ "២"។

៣- តំបន់៣ ស្ថិតនៅទិសបូព៌ា ក្នុងចន្លោះទន្លេមេគង្គលើនិងទន្លេមេគង្គក្រោម តាងដោយលេខ "៣"។

ការកំណត់តំបន់ភូមិសាស្ត្រផ្លូវថ្នល់ខាងលើនេះ ប្រើប្រាស់សម្រាប់តែវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ប៉ុណ្ណោះ។ ផែនទីតំបន់ភូមិសាស្ត្រផ្លូវថ្នល់មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

**មាត្រា ៨.-**

ផ្លូវថ្នល់ដែលទទួលបានការឯកភាពជាគោលការណ៍ពីរាជរដ្ឋាភិបាល ដើម្បីឱ្យដាក់ឈ្មោះផ្លូវឬដាក់លេខផ្លូវហើយ ត្រូវរៀបចំដាក់បញ្ចូលទៅក្នុងផែនទីតំបន់ភូមិសាស្ត្រផ្លូវថ្នល់ និងត្រូវបោះពុម្ពសម្រាប់បម្រើឱ្យវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ព្រមទាំងត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ។

**មាត្រា ៩.-**

ផែនទីតំបន់ភូមិសាស្ត្រផ្លូវថ្នល់ត្រូវធ្វើការត្រួតពិនិត្យនិងរៀបចំជាថ្មីឡើងវិញក្នុងរយៈពេលយ៉ាងយូរ៥(ប្រាំ)ឆ្នាំម្តង និងត្រូវបោះពុម្ពផ្សព្វផ្សាយជាសាធារណៈក្រោយពីបានទទួលការឯកភាពពីរាជរដ្ឋាភិបាល។

ការបញ្ចូលបណ្តាញផ្លូវថ្មីទៅក្នុងផែនទីតំបន់ភូមិសាស្ត្រផ្លូវថ្នល់ និងការបោះពុម្ពផែនទីតំបន់ភូមិសាស្ត្រផ្លូវថ្នល់ ត្រូវធ្វើឡើងដោយគណៈកម្មការជំនាញមួយដែលមានការចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលរាជធានី ខេត្ត និងដែលត្រូវបង្កើតដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា ១០.-**

ផែនទីតំបន់ភូមិសាស្ត្រផ្លូវថ្នល់ អាចផ្តល់ជូនតាមការស្នើសុំរបស់ក្រសួង ស្ថាប័ននានានិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយឥតគិតថ្លៃក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ។

## ជំពូកទី៤
## គោលការណ៍និងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវ
## និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ
### ផ្នែកទី១
### គោលការណ៍នៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវ
### និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ

**មាត្រា ១១.-**

ការដាក់ឈ្មោះផ្លូវឬលេខផ្លូវនិងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

១- ត្រូវកំណត់ទីតាំងនិងចម្ងាយផ្លូវឱ្យបានជាក់លាក់ ទោះបីជាស្ថិតក្នុងស្ថានភាពភូមិសាស្ត្រផ្សេងៗពីគ្នាក៏ដោយ។

២- ត្រូវឱ្យមាននិរន្តរភាពឬភាពតៗគ្នា គឺត្រូវដាក់ឈ្មោះផ្លូវឬលេខផ្លូវនីមួយៗឱ្យរត់តាមទិសដៅតែមួយមានឈ្មោះផ្លូវឬលេខផ្លូវតែមួយក្នុងរយៈចម្ងាយផ្លូវទាំងមូល ឬពីចំណុចចាប់ផ្តើមរហូតដល់ចំណុចបញ្ចប់នៃផ្លូវនីមួយៗ។

**មាត្រា ១២.-**

ការដាក់ផ្លាកឈ្មោះផ្លូវឬលេខផ្លូវ ត្រូវធានាឱ្យមានភាពច្បាស់លាស់ និងស្របតាមស្តង់ដាបច្ចេកទេសដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យផ្លូវថ្នល់ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមមាត្រា៥នៃអនុក្រឹត្យនេះ។

**មាត្រា ១៣.-**

ក្នុងករណីមានការកែប្រែឈ្មោះផ្លូវឬលេខផ្លូវថ្មីដោយសារការវិវឌ្ឍនៃវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ឬករណីប្រធានសក្តិ ត្រូវអនុវត្តតាមគោលការណ៍ដូចមានចែងក្នុងមាត្រា១១នៃអនុក្រឹត្យនេះ ក្រោយពីទទួលបានការឯកភាពឬសេចក្តីសម្រេចឱ្យមានការកែប្រែឈ្មោះផ្លូវឬលេខផ្លូវពីរាជរដ្ឋាភិបាល។

## ផ្នែកទី២
## នីតិវិធីនៃការដាក់ឈ្មោះផ្លូវនិងការកែប្រែឈ្មោះផ្លូវ

**មាត្រា ១៤.-**

ឈ្មោះផ្លូវអាចដាក់ជាឈ្មោះវីរបុរស ឥស្សរជន សប្បុរសជន ឈ្មោះពីប្រវត្តិសាស្ត្រ ឈ្មោះតាមភូមិសាស្ត្រធម្មជាតិ ឈ្មោះតាមវប្បធម៌ ឈ្មោះពីបរមបុរាណ និងឈ្មោះតាមទម្លាប់។

**មាត្រា ១៥.-**

ការដាក់ឈ្មោះផ្លូវឬការកែប្រែឈ្មោះផ្លូវ ត្រូវធ្វើឡើងតាមសំណើរបស់គណៈកម្មាធិការសិក្សាស្រាវជ្រាវនិងរៀបចំបញ្ជីផ្លូវដែលបង្កើតឡើងតាមមាត្រា៦នៃអនុក្រឹត្យនេះ ទៅសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។

**មាត្រា ១៦.-**

ក្នុងករណីមានបណ្តឹងតវ៉ាអំពីការដាក់ឈ្មោះផ្លូវឬការកែប្រែឈ្មោះផ្លូវ សាមីដើមបណ្តឹងត្រូវដាក់ពាក្យប្តឹងទៅគណៈកម្មាធិការសិក្សាស្រាវជ្រាវនិងរៀបចំបញ្ជីផ្លូវដែលជាសេនាធិការជូនសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ដើម្បីពិនិត្យនិងសម្រេច បន្ទាប់ពីមានការឯកភាពពីរាជរដ្ឋាភិបាល។

## ផ្នែកទី៣
## នីតិវិធីនៃការដាក់លេខផ្លូវ

**មាត្រា ១៧.-**

ការដាក់លេខផ្លូវនិងការកំណត់អត្តសញ្ញាណផ្លូវ ត្រូវកំណត់ដូចខាងក្រោម៖

- ចំណុចចាប់ផ្តើមនៃខ្នែងផ្លូវនីមួយៗ ត្រូវជ្រើសរើសក្នុងលក្ខណៈជាទីតាំងដែលមានសក្តានុពលខ្ពស់ផ្នែកសេដ្ឋកិច្ច សង្គម ឬមានប្រជាជនរស់នៅច្រើន ឬមានចរិតជាប្រវត្តិសាស្ត្រ ឬមានស្ពានស្ថិតនៅដើមផ្លូវនៃផ្លូវខ្នែង និងផ្លូវដែលផ្លូវខ្នែងបែកចេញមានអាទិភាពខ្ពស់ជាងផ្លូវដែលផ្លូវខ្នែងតភ្ជាប់
- ផ្លូវបែកចេញពីផ្លូវជាតិឬផ្លូវខេត្ត ត្រូវកំណត់យកលេខសេសសម្រាប់ខាងឆ្វេងដៃ និងលេខគូសម្រាប់ខាងស្តាំដៃ ដោយគិតពីផ្លូវដែលបែកចេញតាមទិសចេញពីរាជធានីភ្នំពេញ ដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ
- តំបន់ភូមិសាស្ត្រផ្លូវថ្នល់ត្រូវបានបែងចែកសម្រាប់កំណត់ទីតាំងផ្លូវនិងដាក់លេខផ្លូវ
- ឈ្មោះរាជធានីនិងខេត្ត ត្រូវតាងដោយអក្សរកាត់សម្រាប់ផ្សំក្នុងការដាក់លេខផ្លូវ ដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ។

**មាត្រា ១៨.-**

ការដាក់លេខផ្លូវត្រូវបានដាក់លេខតាមវិធីសាស្ត្រមួយដែលអាចកំណត់ច្បាស់នូវទីតាំងប្រភេទផ្លូវនិងអាទិភាពផ្លូវ។

ការដាក់លេខផ្លូវ ត្រូវចាប់ផ្តើមពីផ្លូវមានលេខមួយខ្ទង់ រហូតដល់ផ្លូវមានលេខបួនខ្ទង់។

ការដាក់លេខផ្លូវខេត្តនៅក្នុងខេត្ត ត្រូវគួបផ្សំលេខផ្លូវជាមួយអក្សរឡាតាំងដែលជាអក្សរកាត់សម្រាប់សម្គាល់ឈ្មោះខេត្តនោះ។

ឈ្មោះខេត្តជាខេមរភាសានិងជាអក្សរឡាតាំង ដែលសរសេរជាអក្សរកាត់ឡាតាំងសម្រាប់សម្គាល់ឈ្មោះខេត្ត ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យនេះ។

**មាត្រា ១៩.-**

ផ្លូវជាតិកម្រិត១និងផ្លូវជាតិកម្រិត២ ត្រូវបានកំណត់ចំណុចចាប់ផ្តើមនៃទីតាំងមួយនិងចំណុចបញ្ចប់នៃទីតាំងមួយទៀត ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៥នៃអនុក្រឹត្យនេះ។

ចំពោះផ្លូវខេត្តនិងផ្លូវជនបទ ការកំណត់ចំណុចចាប់ផ្តើមនៃទីតាំងមួយនិងចំណុចបញ្ចប់នៃទីតាំងមួយទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យផ្លូវថ្នល់។

## ជំពូកទី៥
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ២០.-**

ឈ្មោះផ្លូវឬលេខផ្លូវដែលបានដាក់ឱ្យប្រើប្រាស់កន្លងមក ត្រូវរក្សាទុកដដែល លើកលែងតែមានការកែប្រែឈ្មោះផ្លូវឬលេខផ្លូវដែលធ្វើឡើងដោយរាជរដ្ឋាភិបាល។

រាជរដ្ឋាភិបាលមានសិទ្ធិដាក់ឈ្មោះផ្លូវថ្មីឬលេខផ្លូវថ្មីតាមការចាំបាច់។

**មាត្រា ២១.-**

ផែនទីនិងតារាងដែលភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ មិនមានឥទ្ធិពលផ្លូវច្បាប់លើការកំណត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជាជាមួយប្រទេសជិតខាងឡើយ។/៕

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ២២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ : ផែនទីតំបន់ភូមិសាស្ត្រផ្លូវថ្នល់នៃអនុក្រឹត្យលេខ.....១០៩.....អនក្រ.បក ចុះថ្ងៃទី ១៧ ខែ មិនា ឆ្នាំ២០១៣ ស្តីពី បែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ(ផែនទីនិងតារាងដែលភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ មិនមានឥទ្ធិពលផ្លូវច្បាប់លើការកំណត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជាជាមួយប្រទេសជិតខាងឡើយ)

Annex1: Roads Regional Map of Sub-decree No. Dated 2013 on Formalities and Procedures of Naming Roads or Numbering Roads and Changing Naming Roads or Numbering Roads (the maps and tables in the attachment of this Sub-decree have no legal effect on the works of the demarcation, between the Kingdom of Cambodia and its Neighboring Countries)



**ឧបសម្ព័ន្ធទី២ :** លេខសេសសម្រាប់ខាងឆ្វេងដៃនិងលេខគូសម្រាប់ខាងស្តាំដៃ ដោយគិតពីផ្លូវដែលបែកចេញតាមទិសចេញពីរាជធានីភ្នំពេញនៃអនុក្រឹត្យលេខ...៦៩... អនក្រ.បក ចុះថ្ងៃទី ១៨ ខែ ៣ ឆ្នាំ២០១៣ ស្តីពីបែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ(ផែនទីនិងតារាងដែលភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ មិនមានឥទ្ធិពលផ្លូវច្បាប់លើការកំណត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជាជាមួយប្រទេសជិតខាងឡើយ)

Annex2 of Sub-decree No. Dated 2013 on Formalities and Procedures of Naming Roads or Numbering Roads and Changing Naming Roads or Numbering Roads (the maps and tables in the attachment of this Sub-decree have no legal effect on the works of the demarcation, between the Kingdom of Cambodia and its Neighboring Countries)



**ឧបសម្ព័ន្ធទី៣ : ឈ្មោះរាជធានីនិងខេត្ត ត្រូវតាងដោយអក្សរកាត់សម្រាប់ផ្សំក្នុងការដាក់លេខផ្លូវនៃ អនុក្រឹត្យលេខ....១១៩....អនក្រ.បក ចុះថ្ងៃទី ១៨ ខែ ៣ ឆ្នាំ២០១៣ ស្តីពីបែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ(ផែនទីនិងតារាងដែលភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ មិនមានឥទ្ធិពលផ្លូវច្បាប់លើការកំណត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជាជាមួយប្រទេសជិតខាងឡើយ)**

Annex3 of Sub-decree No. Dated 2013 on Formalities and Procedures of Naming Roads or Numbering Roads and Changing Naming Roads or Numbering Roads (the maps and tables in the attachment of this Sub-decree have no legal effect on the works of the demarcation, between the Kingdom of Cambodia and its Neighboring Countries)



ឧបសម្ព័ន្ធទី៤ : ឈ្មោះខេត្តជាខេមរភាសានិងជាអក្សរឡាតាំង ដែលសរសេរជាអក្សរកាត់ឡាតាំងសម្រាប់សម្គាល់ឈ្មោះខេត្តនៃអនុក្រឹត្យលេខ..១០៩.......អនក្រ.បក ចុះថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១៣ ស្តីពីបែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ

| | | | |
|---|---|---|---|
| ១- ខេត្តបន្ទាយមានជ័យ | Banteay Meanchey | អក្សរកាត់ឡាតាំង | BM |
| ២- ខេត្តបាត់ដំបង | Battambang | អក្សរកាត់ឡាតាំង | BB |
| ៣- ខេត្តកំពង់ចាម | Kampong Cham | អក្សរកាត់ឡាតាំង | KC |
| ៤- ខេត្តកំពង់ឆ្នាំង | Kampong Chhnang | អក្សរកាត់ឡាតាំង | KCh |
| ៥- ខេត្តកំពង់ស្ពឺ | Kampong Speu | អក្សរកាត់ឡាតាំង | KS |
| ៦- ខេត្តកំពង់ធំ | Kampong Thom | រក្សរកាត់ឡាតាំង | KT |
| ៧- ខេត្តកំពត | Kampot | អក្សរកាត់ឡាតាំង | KP |
| ៨- ខេត្តកណ្តាល | Kandal | អក្សរកាត់ឡាតាំង | KD |
| ៩- ខេត្តកោះកុង | Koh Kong | អក្សរកាត់ឡាតាំង | KK |
| ១០- ខេត្តក្រចេះ | Kratie | អក្សរកាត់ឡាតាំង | KRT |
| ១១- ខេត្តមណ្ឌលគិរី | Mondul Kiri | អក្សរកាត់ឡាតាំង | MK |
| ១២- រាជធានីភ្នំពេញ | Phnom Penh | អក្សរកាត់ឡាតាំង | PP |
| ១៣- ខេត្តព្រះវិហារ | Preah Vihear | អក្សរកាត់ឡាតាំង | PVH |
| ១៤- ខេត្តព្រៃវែង | Prey Veng | អក្សរកាត់ឡាតាំង | PV |
| ១៥- ខេត្តពោធិ៍សាត់ | Pursat | អក្សរកាត់ឡាតាំង | PS |
| ១៦- ខេត្តរតនគិរី | Rattanak Kiri | អក្សរកាត់ឡាតាំង | RK |
| ១៧- ខេត្តសៀមរាប | Siem Reap | អក្សរកាត់ឡាតាំង | SR |
| ១៨- ខេត្តព្រះសីហនុ | Khet Preah Sihanouk | អក្សរកាត់ឡាតាំង | KPS |
| ១៩- ខេត្តស្ទឹងត្រែង | Stung Treng | អក្សរកាត់ឡាតាំង | ST |
| ២០- ខេត្តស្វាយរៀង | Svay Rieng | អក្សរកាត់ឡាតាំង | SVR |
| ២១- ខេត្តតាកែវ | Takeo | អក្សរកាត់ឡាតាំង | TK |
| ២២- ខេត្តឧត្តរមានជ័យ | Oddar Meanchey | អក្សរកាត់ឡាតាំង | ODM |
| ២៣- ខេត្តកែប | Kep | អក្សរកាត់ឡាតាំង | KEP |
| ២៤- ខេត្តប៉ៃលិន | Pailin | អក្សរកាត់ឡាតាំង | PL |

**ឧបសម្ព័ន្ធទី៥ :** ផ្លូវជាតិកម្រិត១នៃអនុក្រឹត្យលេខ...១៨៩.......អនក្រ.បក ចុះថ្ងៃទី ១៨ ខែ ៣ ឆ្នាំ២០១៣ ស្តីពីបែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ(ផែនទីនិងតារាងដែលភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះមិនមានឥទ្ធិពលផ្លូវច្បាប់លើការកំណត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជាជាមួយប្រទេសជិតខាងឡើយ)

Annex5: 1-Digit National Road of Sub-decree No. Dated 2013 on Formalities and Procedures of Naming Roads or Numbering Roads and Changing Naming Roads or Numbering Roads (the maps and tables in the attachment of this Sub-decree have no legal effect on the works of the demarcation, between the Kingdom of Cambodia and its Neighboring Countries)

| លេខផ្លូវ | | ចំណុចផ្តើម | ចំណុចបញ្ចប់ | ប្រវែងគិតជាគីឡូម៉ែត្រ |
|---|---|---|---|---|
| ចាស់ | ថ្មី | | | |
| ១ | ១ | វត្តភ្នំ ( ភ្នំពេញ ) | បាវិត( ព្រំប្រទល់កម្ពុជា វៀតណាម) | ១៦៦,៨៥០ |
| ២ | ២ | គល់ស្ពានព្រះមុនីវង្ស ( ផជ១-គ.ម ៥+០៧៥) | ភ្នំដិន( ព្រំប្រទល់កម្ពុជា វៀតណាម) | ១២០,៦៩៥ |
| ៣ | ៣ | វត្តភ្នំ ( ភ្នំពេញ ) | វាលរិញ( ផជ៤-គ.ម ១៨២+២៨០) | ២០១,៩៨៩ |
| ៤ | ៤ | ចោមចៅ ( ផជ៣-គ.ម ១២+២០០) | ខេត្តព្រះសីហនុ | ២១៤,២០០ |
| ៥ | ៥ | វត្តភ្នំ ( ភ្នំពេញ ) | ប៉ោយប៉ែត( ព្រំប្រទល់កម្ពុជា ថៃ) | ៤០៧,៤៥០ |
| ៦ | ៦ | វត្តភ្នំ ( ភ្នំពេញ ) | សិរីសោភ័ណ( បន្ទាយមានជ័យ) | ៤១៥,៤៧៧ |
| ៧ | ៧ | ស្គន់ ( ផជ៦-គ.ម ៧៥+០០០) | ត្រពាំងគ្រៀល( ព្រំប្រទល់កម្ពុជា ឡាវ) | ៤៦០,៨៣០ |
| | ៨ | ព្រែកតាមាក់ ( ផជ៦-គ.ម ២៤+៣៦០) | ក្រែក( ផជ៧-គ.ម ១៧៥+៥៣០) | ១៣២,៣៥៦ |
| ២១៤ | ៩(*) | ភូមិរាជានុកូល សង្កាត់ស្ទឹងត្រែង ( ផជ៧-គ.ម ៤៥៨) | ភូមិស្គាល់ សង្កាត់ប៉ាល់ហាល់ ក្រុងព្រះវិហារ(ផជ៦២-គ.ម១៣០) | ១៤៣,៣២៦ |
| **ប្រវែងសរុបផ្លូវជាតិកម្រិត១ :** | | | | **២ ២៦២,៧៧៣** |

**បញ្ជាក់ :** - ប្រវែងផ្លូវជាតិលេខ១ លេខ២ លេខ៣ លេខ៤ លេខ៥ និងលេខ៧ កំណត់យកតាមប្រវែងផ្លូវក្នុងប្រកាសលេខ២៥៥៦/[illegible] ខែតុលា ឆ្នាំ១៩៦៩។

- (*) អនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃ[illegible] ក្នុងពិធីបើកការដ្ឋានសាងសង់ផ្លូវនិងស្ពានទន្លេមេគង្គនៅខេត្តស្ទឹងត្រែង នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១២។

**ឧបសម្ព័ន្ធទី៥ :** ផ្លូវជាតិកម្រិត២នៃអនុក្រឹត្យលេខ....១១៩......អនក្រ.បក ចុះថ្ងៃទី ១៨ ខែ មិនា ឆ្នាំ២០១៣ ស្តីពីបែបបទនិង
នីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ(ផែនទីនិងតារាងដែលភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ
មិនមានឥទ្ធិពលផ្លូវច្បាប់លើការកំណត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជាជាមួយប្រទេសជិតខាងឡើយ)

Annex5: 2-Digit National Road of Sub-decree No. Dated 2013 on Formalities and Procedures of Naming Roads or Numbering Roads and Changing Naming Roads or Numbering Roads (the maps and tables in the attachment of this Sub-decree have no legal effect on the works of the demarcation, between the Kingdom of Cambodia and its Neighboring Countries)

| លេខផ្លូវ | ចំណុចផ្តើម | ចំណុចបញ្ចប់ | ប្រវែងគិតជាគីឡូម៉ែត្រ |
|---|---|---|---|
| ១១ | អ្នកលឿង ( ផជ១-គម ៦១+១៥០) | ថ្នល់ទទឹង( ផជ៧-គម ១៣៦+២៥៤) | ៩០,២៨០ |
| ១៣ | ស្វាយរៀង ( ផជ១-គម ១២៦+៥០០) | ឃុំក្របៅ ( ផជ៨-គម ១២៣+២៥៦) | ៥៩,៥០០ |
| ២០ | ក្រាំងស្វាយ ( ផជ២) | កំពង់ទួល ( ផជ៣) | ៩,៦២៤ |
| ២១ | តាខ្មៅ ( ផជ២-គម ១១+០៩០) | ជ្រៃធំ( ព្រំប្រទល់កម្ពុជា វៀតណាម) | ៦៥,៥៦២ |
| ២២ | អូរចំបក់ ( ផជ២-គម ៧៤+០១០) | អង្គតាសោម( ផជ៣-គម ៧៤+៨២០) | ៩,៦១៥ |
| ២៣ | ព្រែកហូរ ( ផជ២) | ភូមិតាព្រហ្ម( ផជ១) | ១២,៣៣០ |
| ៣១ | បំបែកគួស ( ផជ៣-គម ៨១+៩២០) | កំពង់ត្រាច( ផជ៣៣-គម១៨៣+៨១០) | ៥៤,៨១០ |
| ៣២ | កែបថ្មី ( ផជ៣-គម ១៥៦+១០០) | ឧទ្យានជាតិបូកគោ | ៣៣,៣២០ |
| ៣៣ | កំពត ( ផជ៣-គម ១៤៨+១០០) | ប្រកលក( ព្រំប្រទល់កម្ពុជា វៀតណាម) | ៥២,២៧០ |
| ៤១ | ថ្នល់ទទឹង | ល្បាង(ផងទង់) | ៥៦,៤៥០ |
| ៤២ | បែកចាន ( ផជ៤-គម ១៤+០០០) | បាត់ដឹង ( ផជ៥១-គម ១៦+៣០០) | ២៤,២៦០ |

| | | | |
|---|---|---|---|
| ៤៣ | ត្រែងត្រយឹង ( ផជ៤-គម ៨៧+៨៧៧) | ទ្វារថ្មី ( ផជ៣) | ៧៨,៨៨០ |
| ៤៤ | ច្បារមន ( ផជ៤-គម ៤៩+000) | ឧត្តុង្គ ( ផជ៥) | ៨៤,៨៤០ |
| ៤៥ | កងកេង ( ផជ៤-គម ២០៩+១០០) | រាម | ៩,៣០០ |
| ៤៦ | ត្រែងត្រយឹង ( ផជ៤-គម ៨៧+៨៧៧) | ឧទ្យានជាតិគីរីរម្យ | ២៦,៩៥០ |
| ៤៨ | ចំការលួង ( ផជ៤-គម១៤២+៣៥០) | ចាំយាម (ព្រំប្រទល់កម្ពុជា ថៃ) | ១៦១,២៧០ |
| ៥១ | ឧត្តុង្គ ( ផជ៥-គម ៣៨+៥៦០) | ថ្នល់ទទឹង | ៣៨,០១០ |
| ៥២ | ពន្លៃ ( ផជ៥-គម១២៣+៦៤០) | ផ្កុកទ្រូ | ៨,០១០ |
| ៥៣ | កំពង់ឆ្នាំង ( ផជ៥-គ.ម៩១+000) | គោកពេញ | ៦២ |
| ៥៣អា | ឃុំផ្សារ ( ផជ៥) | ក្តុល | ២៩,២៨០ |
| ៥៣បេ | ក្រគរ ( ផជ៥-គម ១៩៣) | កំរែង | ២២,៣០០ |
| ៥៤ | ក្រគរ ( ផជ៥-គម ១៩៣ ) | កំពង់លួង ( ទន្លេសាប) | ៤,៨៧០ |
| ៥៥ | ទីរួមខេត្តពោធិ៍សាត់ ( ផជ៥- គ.ម ១៨៤+៨៥០) | ថ្មដា (ព្រំប្រទល់កម្ពុជា ថៃ) | ១៨៥,២០០ |
| ៥៦ | បន្ទាយមានជ័យ ( ផជ៥-គ.ម ៣៥៩+៧៨០) | ឧត្តរមានជ័យ | ១១៣,៦២០ |
| ៥៧ | បាត់ដំបង ( ផជ៥- គ.ម ២៩១+០១០) | ព្រំ (ព្រំប្រទល់កម្ពុជា ថៃ) | ១០៣,៣៤០ |
| ៥៧បេ | ថ្មគោល ( ផជ៥-គ.ម ៣៣១+២៤០) | សំពៅលូន | ៩០,២០០ |
| ៥៧បេ-១ | បវេល ភូមិសាមសិប | ភ្នំព្រឹក | ៦៩,៧៥០ |
| ៥៧បេ-២ | ភូមិសាមសិប កំរៀង | អូរដា | ១៦,៤០០ |

| | | | |
|---|---|---|---|
| ៥៨ | អូរជ្រៅ ( ផជ៥- គ.ម ៤០៥+៩៩០) | ថ្មដូន | ២៥០,២០០ |
| ៥៩ | កូនដំរី ( ផជ៥-គ.ម ៣៩២+៨២០) | សំពៅលូន — រថក្រោះឆេះ ( ផជ៥៧) | ១៤០,២៥០ |
| ៦០ | សំពងជ័យ ( ផជ៦-គ.ម ៩១+៤៣០ ) | ព្រៃទទឹង ( ផជ៧-គ.ម ៩៥១+១២០ ) | ១៩,៩៤០ |
| ៦១ | ថ្នល់កែង ( ផជ៦-គ.ម ៤៦+៩៩០ ) | ព្រែកក្ដាម ( ផជ៥) | ១៩,៨៩០ |
| ៦២ | ថ្នល់បែក ( ផជ៦-គ.ម ១៧០+៩៥០) | ប្រាសាទព្រះវិហារ | ២៤២,៦៦០ |
| ៦៣ | សៀមរាប( ផជ៦- គ.ម ៣១១+៧២០) | ចុងឃ្នាស ( ភ្នំក្រោម) | ១៤,៣១០ |
| ៦៤ | ដំដែក ( ផជ៦) | ថ្នល់បែក ( ផជ៦២ ) | ១១២,១៦០ |
| ៦៧ | ស្វាយធំ ( ផជ៦) | ជាំ (ព្រំប្រទល់កម្ពុជា ថៃ) | ១៣៣,៨៧០ |
| ៦៨ | ក្រឡាញ់ ( ផជ៦-គ.ម ៣៦៥+៩២៦) | អូរស្មាច់ (ព្រំប្រទល់កម្ពុជា ថៃ) | ១១៦,៨៦០ |
| ៧០ | ព្រៃទទឹង ( ផជ៧-គ.ម ៩៥+២២០) | ពាមជីកង ( កំពង់ចាម) | ១៣,៩៣០ |
| ៧១ | ត្រើង ( ផជ៧-គ.ម ១០៥+៨២២) | កំពង់ថ្ម ( ផជ៦- គ.ម ១២៨+២៤០) | ៥៧,៨៣០ |
| ៧២ | ក្រែក ( ផជ៧-គ.ម ១៧៩+៩៣០) | ត្រពាំងផ្លុង(ព្រំប្រទល់កម្ពុជា វៀតណាម) | ១៣,៥០០ |
| ៧៣ | ប្រធាតុ ( ផជ៧-គ.ម ១៦០+០០០) | ក្រចេះ | ៩២,៤០០ |
| ៧៤ | ស្នួល ( ផជ៧-គ.ម ២៥៤+៩៣០) | ត្រពាំងស្រែ(ព្រំប្រទល់កម្ពុជា វៀតណាម) | ២១,១២០ |
| ៧៦ | ស្នួល ( ផជ៧-គ.ម ២៥៤+៩៣០) | តាអង្គ ( ផជ៧៨-គ.ម ៥៧៥+០០០) | ៣០៦,១៨០ |
| ៧៨ | អូរពងមាន់ ( ផជ៧-គ.ម ៤៥៩+៧០០) | អូរយ៉ាដាវ (ព្រំប្រទល់កម្ពុជា វៀតណាម) | ១៩១,៧០០ |
| ៨៨ | ក្របៅ ( ផជ៨) | មុឺនជ័យ | ៥,៦៣០ |
| **ប្រវែងសរុបផ្លូវជាតិកម្រិត២ :** | | | **៣ ៣៦០,៣១១** |